ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ: ០៤៤៤/០៩ ក.ប/ស.ជ.ណ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការប្រារព្ធខួបអនុស្សាវរីយ៍លើកទី ១២៣ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៩

ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់គ្រប់មន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត សមាគមនិយោជក និង និយោជក សហភាពសហព័ន្ធសហជីព សហព័ន្ធសហជីព និង សហជីព ព្រមទាំងកម្មករ និយោជិតនៃសហគ្រាស គ្រឹះស្ថានទាំងអស់ថា យោង *អនុក្រឹត្យលេខ១៤៣ អនក្រ-បក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីប្រក្រតីទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ២០០៩* និង *ប្រកាសលេខ២១៤ កប/ប្រក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៨ ស្តីពីការឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួលប្រចាំឆ្នាំ២០០៩* សូមអស់លោក លោកស្រី យកចិត្តទុកដាក់នូវប្រការមួយចំនួន ដូចខាងក្រោម :

១- គ្រប់ក្រុមហ៊ុន សហគ្រាស គ្រឹះស្ថាន ត្រូវចាត់ចែងអោយមានការឈប់សំរាក នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៩។ ក្នុងករណីចាំបាច់បំផុត ដែលសហគ្រាស គ្រឹះស្ថានមិនអាចបញ្ឈប់សកម្មភាពរបស់ខ្លួនបានក្នុងឱកាសថ្ងៃឈប់បុណ្យ នេះបានទេ ម្ចាស់ និង នាយកសហគ្រាស គ្រឹះស្ថានត្រូវសម្របសម្រួលជាមួយកម្មករនិយោជិត ឱ្យមានការស្ម័គ្រចិត្ត។ កម្មករនិយោជិត ដែលធ្វើការថ្ងៃឈប់បុណ្យនេះ មានសិទ្ធិទទួលនូវការឈប់សំរាកសងនៅថ្ងៃណាមួយក្នុងសប្តាហ៍ ឬទទួលប្រាក់បំណាច់ ដែល មានចំនួនស្មើនឹងប្រាក់ឈ្នួលថ្ងៃធ្វើការធម្មតា ។

២- សហព័ន្ធសហជីព និង សហជីពតាមសហគ្រាស គ្រឹះស្ថាន ត្រូវសម្របសម្រួល និង សហការជាមួយនិយោជក ដើម្បីចាត់តាំងការជួបជុំនៅតាមសហគ្រាស គ្រឹះស្ថាន ចាត់តាំងកម្មវិធីទទួលអំណរសាទរទិវាពលកម្មអន្តរជាតិ ថ្ងៃទី០១ ខែឧសភា តាមរូបភាពផ្សេងៗ និង តាមលទ្ធភាពរៀងៗខ្លួន ។

៣- សហព័ន្ធសហជីព និង សហជីពតាមសហគ្រាស គ្រឹះស្ថានទាំងឡាយ ពុំគប្បីយកឱកាសទិវាពលកម្មអន្តរជាតិ ថ្ងៃ ទី០១ ខែឧសភា ដែលជាថ្ងៃបុណ្យការងារ និង ជាថ្ងៃឈប់សំរាកការងាររបស់កម្មករនិយោជិត ដើម្បីបង្កនូវបាតុភាពទាំងឡាយ ណា ដែលនាំឱ្យមានអំពើហឹង្សា ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈរបស់សង្គម ឬ រំខានដល់គោលបំណងខាងលើឡើយ ។

-ក្នុងន័យនេះ សហព័ន្ធសហជីព គប្បីចាត់តាំងពិធីជួបជុំសំណេះសំណាលអបអរសាទរទិវាពលកម្មអន្តរជាតិ ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៩ នៅតាមទីស្នាក់ការសហព័ន្ធរៀងៗខ្លួន ដើម្បីត្រងត្រាប់ស្តាប់ ឬ ផ្សព្វផ្សាយ **សារលិខិតរបស់ សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា** សារាចរណែនាំរបស់រាជរដ្ឋាភិបាល

កម្ពុជា និង **សេចក្តីជូនដំណឹងរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ** ព្រមទាំងធ្វើការប្រារព្ធពិធីកំសាន្តសប្បាយរីករាយតាមរូបភាព និង លទ្ធភាពជាក់ស្តែង ។

-សូមអស់លោក លោកស្រី សហការឱ្យបានជិតស្និទ្ធជាមួយអាជ្ញាធរមានសមត្ថកិច្ចថែរក្សាសន្តិសុខ សុវត្ថិភាព និង សណ្តាប់ធ្នាប់សាធារណៈ ដើម្បីបង្កលក្ខណៈងាយស្រួលដល់កម្មវិធីសប្បាយរីករាយរបស់កម្មករនិយោជិត តាមសហគ្រាស គ្រឹះស្ថាន ដែលបោះទីតាំងក្នុងមូលដ្ឋាន ។

ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ មានក្តីសង្ឃឹមយ៉ាងមុតមាំថា សមាគមនិយោជក និង និយោជក ព្រមទាំង សហព័ន្ធសហជីព និង កម្មករនិយោជិត នៃសហគ្រាស គ្រឹះស្ថានទាំងអស់ ប្រាកដជាអនុវត្តតាមសេចក្តីជូនដំណឹងនេះបានល្អប្រសើរជាពុំខាន ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០០៩

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**វង្ស សុត**

**ចម្លងជូន :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យលោកឧបនាយករដ្ឋមន្ត្រីប្រចាំការ

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

-អគ្គនាយកដ្ឋានការងារ

-អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ

-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និង ហិរញ្ញវត្ថុ

-គ្រប់មន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត

"ដើម្បីផ្សព្វផ្សាយ និង អនុវត្ត"

-សមាគមនិយោជក "ដើម្បីជ្រាប-អនុវត្ត"

-សហព័ន្ធសហជីព "ដើម្បីជ្រាប-អនុវត្ត"

-គ្រប់បណ្តាញវិទ្យុ និង ទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"

-រាជកិច្ច

-ឯកសារ-កាលប្បវត្ត